ទម្រង់ទី២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលា ខេត្តបន្ទាយមានជ័យ
លេខ...៣៥០១.សខ៧

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៥**

អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៥ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៥ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំសង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ៖

- ប្រភេទទី១៖អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារនិងការងារបេតុង ...។ល។)
- ប្រភេទទី២៖អ្នកទទួលការការងារដី (ប្រឡាយទំនប់ផ្លូវដីសផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេសឧទាហរណ៍អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេសនិងសម្ភារៈបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និង វាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជីព្រមទាំងពិនិត្យមើលគុណភាពការងារភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលរាជធានីខេត្តដើម្បីពិនិត្យនិងសម្រេច ។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នាការក្លែងបន្លំ និងអំពើពុករលួយហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការអ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការសូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការនិងវិនិយោគនៃសាលា រាជធានី ខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ **ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៤ វេលាម៉ោង១៧ល្ងាច** ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការដោយឥតបង់ថ្លៃតាមអាសយដ្ឋាន*អាគារជួរក្រោយក្នុងបរិវេណសាលាខេត្តបន្ទាយមានជ័យ* ឬអាចទាញយកពីគេហទំព័ររបស់គ.ជ.អ.ប។

បន្ទាយមានជ័យ,ថ្ងៃទី......ខែ............ឆ្នាំ២០១៤

**អភិបាលខេត្ត**

គោស៊ុំ សារឿត

<u>ចម្លងជូន</u>
- -ក្រសួងមហាផ្ទៃ
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -លេខាធិការដ្ឋាន គ.ជ.អ.ប
- -ទីប្រឹក្សាកម្មវិធីជាតិថ្នាក់ខេត្ត (ដើម្បីគោរពជូនជ្រាប)
- -គ្រប់សាលាស្រុក ក្រុង ឃុំ សង្កាត់ (ដើម្បីផ្សព្វផ្សាយ)
- -ឯកសារ-កាលប្បវត្តិ